**បទបង្ហាញ**

**របស់**

**ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ស្តីពីដំណើរការនៃការរៀបចំ**

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និង តម្រូវការធនធាន**

**នាកិច្ចប្រជុំ GDCC លើកទី១៩ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១២**

**សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយត្រូវបានផ្តល់ឱកាស ឲ្យធ្វើបទបង្ហាញសង្ខេប ដល់ កិច្ចប្រជុំ GDCC លើកទី១៩ អំពីដំណើរការនៃការរៀបចំ ផែនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ថ្មីមួយ សម្រាប់រយៈពេល៥ឆ្នាំ ពោលគឺ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ឆ្នាំ២០១៤-២០១៨** និង **តម្រូវការធនធានសម្រាប់ ដំណើរការខាងនេះ**។

ខ្ញុំសូមចាប់ផ្តើមដោយធ្វើការគូសបញ្ជាក់ថា **ផយអជ** ដើរតួនាទីយ៉ាងសំខាន់ ជាឧបករណ៍គោលនយោបាយចម្បង សម្រាប់ការអនុវត្តចក្ខុវិស័យនៃការអភិវឌ្ឍជាតិ ដូចមានចែងនៅក្នុងកម្មវិធីគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីធានាឲ្យមាននូវ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ជាតិមួយដែលមានសង្គតិភាព ទិសដៅគោលនយោបាយរបស់ **ផយអជ ២០១៤-២០១៨** ត្រូវបន្សុីគ្នាជាមួយនឹងបណ្តាគោលដៅចម្បងៗនៃការអភិវឌ្ឍជាតិរបស់ រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ខាងមុខនេះ។ ទន្ទឹមនឹងនេះ តាមរយៈ**ផយអជ** រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីថែរក្សាឲ្យបាននូវសមិទ្ធផលដែលសម្រេចបានកន្លងមក។ ដើម្បីជាការត្រៀមលក្ខណៈចំពោះការប្រែប្រួលឥតឈប់ឈរនៃកត្តាក្នុងនិងក្រៅប្រទេស រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់នូវភាពចាំបាច់ក្នុងការធានាថា **ផយអជ ២០១៤-២០១៨** នឹងគិតគូររំពឹងទុកដល់បណ្តាកាលានុវត្តភាពនិងបញ្ហាប្រឈមដែលនឹងកើតមានឡើងក្នុងពេលខាងមុខ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការកំណត់នូវគោលនយោបាយនិងយុទ្ធសាស្ត្រនានា ឲ្យបានសមស្របទៅនឹងបរិការណ៍នៃការអភិវឌ្ឍដែលកំពុងកើតមាន។

ក្របខ័ណ្ឌគោលនយោបាយនិងបរិការណ៍នៃការអភិវឌ្ឍ ដែលផ្តល់ការតម្រង់ទិសដល់ **ផយអជ** ២០១៤-២០១៨ រួមមាន **យុទ្ធសាស្ត្រចតុកោណ ដំណាក់ កាលទី២** (ឬយុទ្ធសាស្ត្រថ្មីមួយ) -- ការរកឃើញរបស់ **របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០១១ ស្តីពីការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម** ២០០៩-២០១៣ -- កត្តាវិវឌ្ឍឥតឈប់ឈរទាំងក្នុងនិងក្រៅប្រទេសដែលកម្ពុជាជួបប្រទះ -- និង កិច្ចខិតខំប្រឹងប្រែងដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវបន្តយកចិត្តទុកដាក់ ៖ (១) ដើម្បីធ្វើឲ្យកម្ពុជាចេញផុតពីស្ថានភាពជាប្រទេសដែលមានការអភិវឌ្ឍតិចតួច (២) ដើម្បីធ្វើសមាហរណកម្មកម្ពុជាទៅក្នុង ASEAN (៣) ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅភាគច្រើននៃ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** (៤) ដើម្បីដឹកនាំកម្ពុជានៅលើមាគ៌ាមួយសំដៅទៅរកការអភិវឌ្ឍដែលមានភាពគ្រប់ដណ្តប់គ្រប់ជ្រុងជ្រោយនិងប្រកបដោយចីរភាព ហើយ ជាគោលដៅចុងក្រោយបង្អស់ គឺដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ខ្ញុំនឹងធ្វើការផ្តោតលើទិដ្ឋភាពសំខាន់ពីរដែលផ្តល់ការតម្រង់ទិសដល់ **ផយអជ** ២០១៤-២០១៨ គឺ ៖ បរិការណ៍នៃការអភិវឌ្ឍ (បញ្ហាប្រឈមនិងកាលានុវត្តភាពដែលនឹងអាចមាន)និង ទិសដៅចម្បងៗរបស់ផែនការនេះ។

***<u>ចំពោះបញ្ហាប្រឈម</u> ៖*** ដោយសារកត្តាខាងក្រៅបាននិងកំពុងបន្តកើតមាន នោះកម្ពុជានឹងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន។ នៅក្នុងបញ្ហាប្រឈមទាំងនោះ ការត្រៀមខ្លួនដើម្បីការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងអាស៊ាន គឺជាកិច្ចការដែលត្រូវយកមកគិតគូរ។ ជាមួយគ្នានេះដែរ កម្ពុជាត្រូវត្រៀមខ្លួនដើម្បីចេញពីស្ថានភាពជាប្រទេសដែលមានការអភិវឌ្ឍតិចតួច ពោលគឺ យើងនឹងត្រូវធ្វើការអភិវឌ្ឍប្រទេសដោយមាន ជំនួយឥតសំណងឬឥណទានសម្បទានតិចជាងមុន និង ភាពមិនងាយស្រួលក្នុងការទទួលបានលក្ខខណ្ឌអនុគ្រោះសម្រាប់ទីផ្សារនាំចេញ។ លើសពីនេះ ចំហាយនៃវិបត្តិសេដ្ឋកិច្ចសាកល និង វិបត្តិបំណុលនៅអឺរ៉ុបនឹងបន្តមានការប៉ះពាល់មកលើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍តូចៗដូចជា ប្រទេសយើង។

ដូចបានបញ្ជាក់ច្បាស់នៅក្នុង **របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ ស្តីពី ការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម** ២០០៩-២០១៣ បញ្ហាកំពុងប្រឈមនៅក្នុងប្រទេសដែលយើងបាននិង

កំពុងជួបប្រទះ រួមមាន ៖ ភាពខ្វះខាតនូវធនធានរូបវន្តនិងធនធានមនុស្ស -- ភាពចាំបាច់ក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈឲ្យកាន់តែស៊ីជម្រៅជាងមុន -- ភាពចាំបាច់ក្នុងការធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្របសម្រួលរវាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល -- ភាពចាំបាច់ក្នុងការបន្តជំរុញកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ -- ភាពចាំបាច់ក្នុងការកាត់បន្ថយឲ្យបានច្រើនបំផុតនូវ ការអនុវត្តការងារតាម ***វិធីសាស្ត្រផ្អែកលើគម្រោង*** ហើយឈានទៅរកការអនុវត្ត***អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីឬទូទាំងវិស័យ*** -- និង ភាពចាំបាច់ក្នុងការពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

***<u>ចំពោះកាលានុវត្តភាព</u>*** ***៖*** ទន្ទឹមនឹងបញ្ហាប្រឈមដែលខ្ញុំបានជម្រាបជូនខាងលើ ក៏មានកាលានុវត្តភាពជាច្រើនដែលកម្ពុជាអាចទាញយកប្រយោជន៍បាន រួមមាន ៖ កម្ពុជាអាចទទួលផលប្រយោជន៍ពី «ភាពអំណោយផលផ្នែកប្រជាសាស្ត្រ» -- គោលនយោបាយព្រៃឈើបាននិងកំពុងជំរុញការបង្កើនគម្របព្រៃពណ៌បៃតង ដែលជួយយើងអាចរួមចំណែកក្នុងការកាត់បន្ថយការឡើងកំដៅសាកល -- ប្រភពធនធានរ៉ែដែលត្រូវបានរកឃើញថ្មីៗ នឹងអាចផ្តល់ផលប្រយោជន៍សម្រាប់ប្រទេសនិងប្រជាជន -- ហើយ ការកើនឡើងនៃតម្លៃពលកម្មនៅក្នុងបណ្តាប្រទេសជិតខាង អាចផ្តល់កាលានុវត្តភាពដល់កម្ពុជា ក្នុងការអភិវឌ្ឍឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើន។

***<u>ចំពោះទិសដៅគន្លឹះសំខាន់ៗ</u>*** ***៖*** ដើម្បីដោះស្រាយបញ្ហាប្រឈមនានា និង ទាញយកប្រយោជន៍ពីកាលានុវត្តភាព ដូចបានគូសបញ្ជាក់ខាងលើ ទិសដៅចម្បងៗរបស់ ផយអជ ២០១៤-២០១៨ នឹងផ្តោតលើ អាទិភាពរួមមួយចំនួននៃការអភិវឌ្ឍ ដូចខាងក្រោម ៖

- **<u>ការបង្កើតបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍដែលមានមូលដ្ឋានធំទូលាយនិងមានតាពគ្របដណ្តប់គ្រប់ជ្រុងជ្រោយ</u>** ៖ ដើម្បីបង្កើតបុរេលក្ខខណ្ឌសម្រាប់ «ការអភិវឌ្ឍដែលមានមូលដ្ឋានធំទូលាយនិងមានតាពគ្របដណ្តប់គ្រប់ជ្រុងជ្រោយ» រាជរដ្ឋាភិបាលកម្ពុជានឹង បន្តពង្រឹងសុខសន្តិភាពនិងស្ថេរភាពនយោបាយ -- បន្តកិច្ចខិខំប្រឹងប្រែងក្នុងការពង្រឹងអភិបាលកិច្ចល្អ បន្តពង្រឹងការងារវិមជ្ឈការនិងវិសហមជ្ឈការ -- ព្រមទាំង បន្តជំរុញលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជននិងភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។

- **<u>វិស័យសេដ្ឋកិច្ច</u>** ៖ កិច្ចខិតខំប្រឹងប្រែងនានានឹងធ្វើការផ្តោតលើទិដ្ឋភាពសំខាន់ចំនួន៣ ៖

  ក. <u>ជំរុញឲ្យមានកំណើនដែលមានមូលដ្ឋានធំទូលាយនិងមាននាពគ្របដណ្តប់គ្រប់ជ្រុងជ្រោយ</u> ៖ ទិសដៅចម្បង ត្រូវផ្តោតលើអាទិភាពរួមចំនួន៤ នៅក្នុងការងារនេះ ៖

  - ➢ បង្កលក្ខណៈឲ្យមានទំនើបភាវូបនីយកម្មក្នុងវិស័យកសិកម្ម និង ជំរុញការបង្កើនទិន្នផល។
  - ➢ លើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន សម្រាប់ការធ្វើ ឧស្សាហូបនីយកម្ម និងទំនើបភាវូបនីយកម្មដែលមានមូលដ្ឋានធំទូលាយ។
  - ➢ បន្តការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។
  - ➢ បង្កើតនូវបរិស្ថានសេដ្ឋកិច្ចឬធុរៈកិច្ចសម្រាប់ការងារសមរម្យថ្លៃថ្នូរ។

  ខ. <u>បង្កើតបរិស្ថានសម្រាប់សេដ្ឋកិច្ចបើកចំហដែលមានតុល្យភាព</u> ៖ ទិសដៅចម្បង ត្រូវផ្តោតលើអាទិភាពរួមចំនួន៣ នៅក្នុងការងារនេះ ៖

  - ➢ បង្កើន ការនាំចេញ និង ភាពបើកចំហនៃសេដ្ឋកិច្ចកម្ពុជា។
  - ➢ ជំរុញកម្ពុជាឲ្យ ចេញពីស្ថានភាពជា *ប្រទេសដែលមានការអភិវឌ្ឍតិចតួច* ហើយ ឲ្យក្លាយជាប្រទេសមួយដែលនៅក្នុងស្ថានភាពជា *ប្រទេសដែលមានការស្ទុះឡើងផ្នែកសេដ្ឋកិច្ច*។
  - ➢ ត្រៀមរៀបចំកម្ពុជាសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ ASEAN ។

  គ. <u>បង្កើន ចំណេះដឹង និង ការអនុវត្តបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា</u>។

- **<u>ការអភិវឌ្ឍមនុស្សនិងសង្គម</u>** ៖ កិច្ចខិតខំប្រឹងប្រែងនានានឹងធ្វើការផ្តោតលើ ការកាត់បន្ថយភាពក្រីក្រ សមភាព ការអប់រំ និង សុខភាព។

  - ➢ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាធ្វើការ កាត់បន្ថយភាពក្រីក្រ និង កាត់បន្ថយវិសមភាពក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដូចជា ទិដ្ឋភាពនៃការងារនេះជាលក្ខណៈតំបន់ ទិដ្ឋភាពអប់រំ ទិដ្ឋភាពសុខាភិបាល ទិដ្ឋភាពនៃការទទួលបានកាលានុវត្តភាព និង ទិដ្ឋភាពផ្សេងៗទៀត។ ចំណុចដៅសមស្រប នឹងត្រូវកំណត់សម្រាប់ទិដ្ឋភាពទាំងអស់នេះ។

- សង្គមកម្ពុជាគួរក្លាយជាសង្គមមួយដែលមានមូលដ្ឋានចំណេះដឹងរឹងមាំ នាពេលអនាគត។ ដើម្បីសម្រេចបានទិសដៅនេះ យើងនឹង កំណត់ចំណុចដៅជាបរិមាណនៅកម្រិតនីមួយៗនៃការអប់រំនិងការបណ្តុះបណ្តាល -- លើកកម្ពស់គុណភាពនៃការអប់រំ -- និង ពង្រឹងធនធានមនុស្ស និង សមត្ថភាពខាងផ្នែកបច្ចេកវិទ្យា។
- យើងនឹងខិតខំដើម្បីសម្រេចឲ្យបានប្រកបដោយចីរភាព នូវចំណុចដៅនានារបស់ ***គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា*** និង ត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ក្រោយឆ្នាំ២០១៥ ក្នុងវិស័យមួយចំនួន ដូចជា ៖ សុខាភិបាល យេនឌ័រ កុមារនិងយុវជន ទឹកស្អាតនិងអនាម័យ បរិស្ថាន និង ទិដ្ឋភាពផ្សេងៗទៀតសម្រាប់សុខុមាលភាពរបស់ប្រជាជន។

- **<u>បញ្ហាអន្តរវិស័យ</u>** ៖ រាជរដ្ឋាភិបាល បានចាត់ទុកបញ្ហាចំនួនពីរ ជាបញ្ហាអន្តរវិស័យ គឺ ៖ យេនឌ័រនិងការប្រែប្រួលអាកាសធាតុ ហើយ នឹងយកចិត្តទុកដាក់បញ្ជ្រាបបញ្ហាអន្តរវិស័យទាំងពីរនេះទៅក្នុងគ្រប់វិស័យទាំងអស់ ដូចជា វិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច និង វិស័យផ្សេងៗទៀត។ ទន្ទឹមនឹងនេះ កម្ពុជានឹងរួមចំណែកនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោក ក្នុងការទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ។ បញ្ហាអន្តរវិស័យផ្សេងៗទៀតនឹងត្រូវកំណត់បន្ថែម នៅក្នុងដំណាក់កាលបន្ទាប់។

- **<u>ការបោសសម្អាតមីន</u>** ៖ ផ្ទៃដីមួយភាគធំត្រូវរងផលប៉ះពាល់ដោយសារគ្រាប់មីន ហើយ ការបោសសម្អាតមីន គឺជា កិច្ចការមួយដែលរាជរដ្ឋាភិបាលនឹងបន្តដោះស្រាយនៅក្នុងពេលខាងមុខ។

- **<u>ការតាមដាននិងត្រួតពិនិត្យ</u>** ៖ ជាមួយនឹងវិស័យសេដ្ឋកិច្ចដែលកាន់តែមានលក្ខណៈស្មុគស្មាញឡើងៗ ការធ្វើឲ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃមួយដែលមានលក្ខណៈប្រមូលផ្តុំ គឺជាភាពចាំបាច់។ ការចាប់ផ្តើមក្នុងលក្ខណៈសាមញ្ញត្រូវបានធ្វើឡើងនៅគ្រប់កម្រិតទាំងអស់ ដូចជា នៅថ្នាក់ជាតិ នៅកម្រិតវិស័យ និង នៅថ្នាក់ក្រោមជាតិ។ កិច្ចខិតខំប្រឹងប្រែងនេះនឹងត្រូវធ្វើឲ្យលក្ខណៈស៊ីជម្រៅជាងមុន ដើម្បីធ្វើឲ្យការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ក្លាយជាផ្នែកមួយនៃដំណើរការរបស់ផែនការ

ជាតិ។ កិច្ចខិតខំប្រឹងប្រែងក៏នឹងត្រូវធ្វើឡើងផងដែរ ដើម្បីកំណត់សូចនាករឲ្យបានច្រើនជាងមុនសម្រាប់ធ្វើការវាយតម្លៃពីលទ្ធផល (outcomes) ឧទាហរណ៍ដូចជាកំណើនដែលមានភាពគ្របដណ្តប់គ្រប់ជ្រុងជ្រោយ -- ភាពប្រសើរឡើងនៃអភិបាលកិច្ច (ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញពី ការឆ្លើយតប តម្លាភាព និង គណនេយ្យភាព) និង ដើម្បីពង្រឹងមូលដ្ឋានទិន្នន័យសម្រាប់សេដ្ឋកិច្ចកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ខ្ញុំសូមយកឧកាសនេះជម្រាបជូនអង្គប្រជុំដោយសង្ខេបអំពី ដំណើរការនៃការរៀបចំ **ផយអជ** ២០១៤-២០១៨ ដែលចែកជាពីរដំណាក់កាល ៖ *(១)* ដំណាក់កាលត្រៀម និង *(២)* ដំណាក់កាលនៃការរៀបចំ។ ខ្ញុំសូមធ្វើការបញ្ជាក់ជូនអង្គប្រជុំផងដែរថា ដើម្បីបង្កលក្ខណៈឲ្យមានវិធីសាស្ត្រដែលមានការចូលរួមនៅក្នុងការរៀបចំឯកសារជាតិនេះ ដំណើរការមួយដែលមានការពិគ្រោះយោបល់ នឹងត្រូវបង្កើតឡើង ដើម្បីផ្តល់ឱកាស ឲ្យអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ក្នុងរដ្ឋាភិបាល (ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ) ផ្តល់នូវធាតុចូលនិងអនុសាសន៍ មកក្រសួងផែនការដែលជាស្ថាប័នសម្របសម្រួល តាមរយៈកិច្ចសហការអន្តរក្រសួងដូចធ្លាប់បានអនុវត្តកន្លងមក និង ឲ្យដៃគូអភិវឌ្ឍន៍នានាផ្តល់មតិឬអនុសាសន៍ដល់ដៃគូរបស់ខ្លួនក្នុងរដ្ឋាភិបាល តាមរយៈយន្តការដែលមានស្រាប់ ពោលគឺ យន្តការក្រុមការងារបច្ចេកទេសចម្រុះ។

កាលបរិច្ឆេទនៃដំណើរការរៀបចំមានដូចខាងក្រោម ៖

**<u>ដំណាក់កាលត្រៀម (ឆ្នាំ២០១២)</u> ៖**

សេចក្តីព្រាងឯកសារទស្សនាទាន សម្រាប់ការរៀបចំ **ផយអជ** ២០១៤-២០១៨ ត្រូវបានរៀបចំឡើង នៅក្នុង ខែមិថុនា ឆ្នាំ២០១២ និង ត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំរបស់អនុក្រុមនៃក្រុមការងារបច្ចេកទេសចម្រុះផែនការនិងកាត់បន្ថយភាពក្រីក្រ និង នៅក្នុងការប្រជុំផ្ទៃក្នុងក្រសួងផែនការ។ សេចក្តីព្រាងឯកសារនេះ នឹងត្រូវផ្ញើជូនក្រសួង ស្ថាប័ន និង ដៃគូអភិវឌ្ឍន៍នានា នាដើមខែតុលា ឆ្នាំ២០១២។ យើងមានការជឿជាក់យ៉ាងមាំថា ក្នុងរយៈពេលប្រមាណជិតពីរខែ (តុលានិងវិច្ឆិកា) ដំណើរការពិគ្រោះយោបល់នៅក្នុងចំណោមក្រសួង ស្ថាប័ននិងដៃគូអភិវឌ្ឍន៍ តាមរយៈ យន្តការនៃក្រុមការងារបច្ចេកទេសចម្រុះ និង

កិច្ចប្រជុំអន្តរក្រសួង នឹងផ្តល់នូវអនុសាសន៍ដ៏មានតម្លៃ សម្រាប់ការកែលម្អសេចក្តីព្រាង ឯកសារទស្សនាទាននេះ។ នៅដើម ខែធ្នូ ឆ្នាំ២០១២ នឹងមានកិច្ចប្រជុំកម្រិតខ្ពស់នៃស្ថាប័នកណ្តាលចំនួនបួន ដែលនឹងប្រារព្ធឡើងដោយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងឯកសារទស្សនាទាននេះ ដែលយើងនឹងយកធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំ *សារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ ផយអវ ២០១៤-២០១៨*។ សារាចរ នេះ នឹងក្លាយជាគោលការណ៍ណែនាំ របស់រាជរដ្ឋាភិបាល សម្រាប់ការរៀបចំ ផយអវ ២០១៤-២០១៨ ហើយ នឹងត្រូវ ចុះហត្ថលេខាដោយប្រមុខរាជរដ្ឋាភិបាល និង ផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធ នៅដំណាច់ ខែធ្នូ ឆ្នាំ២០១២ ឬ ដើមខែមករា ឆ្នាំ២០១៣។

**ដំណាក់កាលនៃការរៀបចំ (ឆ្នាំ២០១៣)** ៖

- **នៅ ខែមករា ឆ្នាំ២០១៣** ៖ កិច្ចប្រជុំអន្តរក្រសួងលើកដំបូង នឹងប្រារព្ធឡើង ដើម្បីប្រកាសផ្សព្វផ្សាយ *សារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ ផយអវ ២០១៤-២០១៨* និង ពិភាក្សាអំពីការរៀបចំធាតុចូលរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ស្តីពី «ការអនុវត្តកន្លងមកនិងការស្នើឡើងនូវគោលនយោបាយនិងសកម្មភាពថ្មីៗ»។
- **ពី ខែមករា ដល់ ខែមេសា ឆ្នាំ២០១៣** ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំ ធាតុចូលស្តីពី «ការអនុវត្តកន្លងមកនិងការស្នើឡើងនូវគោលនយោបាយនិងសកម្មភាពថ្មីៗ» សម្រាប់ការងារក្នុងវិស័យរបស់ខ្លួន។
- **នៅដើម ខែឧសភា ឆ្នាំ២០១៣**៖ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្ញើ ធាតុចូលស្តីពី «ការអនុវត្តកន្លងមកនិងការស្នើឡើងនូវគោលនយោបាយនិងសកម្មភាពថ្មីៗ»មកក្រសួងផែនការ។
- **ពី ខែឧសភា ដល់ ខែកក្កដា ឆ្នាំ២០១៣**៖ ក្រសួងផែនការរៀបចំសេចក្តីព្រាង ផយអវ ២០១៤-២០១៨ ។
- **នៅ ខែសីហា ឆ្នាំ២០១៣** ៖ សេចក្តីព្រាង ផយអវ ២០១៤-២០១៨ នឹងត្រូវធ្វើការពិភាក្សាជាមួយនឹង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ធ្វើការព្យាករពីលទ្ធភាពហិរញ្ញវត្ថុ និងការបន្សុីគ្នាជាមួយនឹង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម បើសិនជាធ្វើបាន។
- **ពី ខែសីហា ដល់ ខែកញ្ញា ឆ្នាំ២០១៣** ៖ សេចក្តីព្រាង ផយអវ ២០១៤-២០១៨ នឹងត្រូវផ្ញើជូនក្រសួង ស្ថាប័ន សម្រាប់ការផ្តល់អនុសាសន៍។
- **ពី ខែសីហា ដល់ ខែកញ្ញា ឆ្នាំ២០១៣**៖ សេចក្តីព្រាង ផយអវ ២០១៤-២០១៨ នឹងត្រូវធ្វើការពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍន៍ តាមរយៈយន្តការក្រុមការងារបច្ចេកទេសចម្រុះ។

- <u>នៅ ខែតុលា ឆ្នាំ២០១៣</u> ៖ កិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសដើម្បីពិនិត្យលើសេចក្តីព្រាង ផយអវ ២០១៤-២០១៨ ។
- <u>នៅ ចុងខែតុលា ឆ្នាំ២០១៣</u> ៖ កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងជាមួយនឹងថ្នាក់ដឹកនាំក្រសួងផែនការ ដើម្បីពិនិត្យលើ សេចក្តីព្រាង ផយអវ ២០១៤-២០១៨ ដែលបានកែសម្រួលបន្ទាប់កិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស។
- <u>នៅដើម ខែវិច្ឆិកា ឆ្នាំ២០១៣</u>៖ កិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយដើម្បីពិនិត្យលើសេចក្តីព្រាង ផយអវ ២០១៤-២០១៨ ។
- <u>នៅពាក់កណ្តាល ខែវិច្ឆិកា ឆ្នាំ២០១៣</u>៖ កិច្ចប្រជុំកម្រិតខ្ពស់នៃស្ថាប័នកណ្តាលចំនួនបួន ដែលនឹងត្រូវរៀបចំឡើងដោយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាង ផយអវ ២០១៤-២០១៨ ។
- <u>នៅចុង ខែវិច្ឆិកា ឆ្នាំ២០១៣</u>៖ កិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រីដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាង ផយអវ ២០១៤-២០១៨។
- <u>នៅចុង ខែធ្នូ ឆ្នាំ២០១៣</u>៖ សភាជាតិ (រដ្ឋសភានិងព្រឹទ្ធសភា) ពិនិត្យនិងផ្តល់ការឯកភាពលើ ផយអវ ២០១៤-២០១៨។

**<u>ធនធានដែលត្រូវការបន្ថែមសម្រាប់ដំណើរការនៃការរៀបចំ ផយអវ ២០១៤-២០១៨</u> ៖**

អាស្រ័យដោយហេតុថា ការរៀបចំ ផយអវ ២០១៤-២០១៨ នឹងត្រូវការនូវធនធានបន្ថែមសម្រាប់ដំណើរការការងារនេះ ខ្ញុំសូមធ្វើការបង្ហាញដោយសង្ខេប អំពីមុខចំណាយដែលយើងត្រូវការកិច្ចសហប្រតិបត្តិការគាំទ្រពីដៃគូអភិវឌ្ឍន៍ ៖

1. **<u>ដំណាក់កាលត្រៀម (ឆ្នាំ២០១២)</u>**៖ តម្រូវការធនធានសម្រាប់សកម្មភាពការងារក្នុងដំណាក់កាលត្រៀមនេះ ត្រូវបានបំពេញ ដោយការគាំទ្រពី UNFPA, UNDP, និង UNICEF ។
2. **<u>ដំណាក់កាលនៃការរៀបចំ ផយអវ ២០១៤-២០១៨ (ឆ្នាំ២០១៣)</u>**៖

   ២.១ ស្នើសុំបន្តសេវាកម្មជំនួយបច្ចេកទេសដែលកំពុងគាំទ្រដោយ UNDP។
   ២.២ ការរៀបចំសកម្មភាពនានា ដូចជា កិច្ចប្រជុំ ឬ សិក្ខាសាលា។
   ២.៣ ការរៀបចំទស្សនកិច្ចសិក្សានៅបរទេស។
   ២.៤ ការបោះពុម្ពឯកសារ។
   ២.៥ សំភារៈសម្រាប់ដំណើរការងារ។

3. **<u>ចំណាយសម្រាប់សេវាកម្មផ្សេងៗ</u>**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ខ្ញុំសូមបញ្ចប់ការធ្វើបទបង្ហាញសង្ខេបស្តីពី ដំណើការនៃការរៀបចំ ផយអជ ២០១៩-២០១៨ និង តម្រូវការធនធានសម្រាប់ការងារនេះ ហើយ ខ្ញុំសូមសម្តែងនូវក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួងផែនការនឹងទទួលបាននូវកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កានិងប្រកបដោយប្រសិទ្ធភាព អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ទាំងពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ទាំងពីដៃគូអភិវឌ្ឍន៍ សម្រាប់ភារៈកិច្ចដ៏សំខាន់នេះ។

សូមអរគុណ៕